# កម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ រដ្ឋម៉ាសាជូសេត

រដ្ឋ Commonwealth កំពុងតែធ្វើការជាមួយគណៈសុខភាពក្នុងតំបន់ បានបង្កើតកម្មវិធីមួយទូទាំងរដ្ឋ ដើម្បីផ្តល់ជូនការចាក់វ៉ាក់សាំង-ក្នុងផ្ទះ សំរាប់បុគ្គលគាំងនៅក្នុងផ្ទះ ដែលមិនអាចចេញពីផ្ទះរបស់គេ ទៅកន្លែងចាក់វ៉ាក់សាំងបាន។

## សិទ្ធិទទួលកម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ រដ្ឋម៉ាសាជូសេត

**ការចាក់វ៉ាក់សាំង-ក្នុងផ្ទះ គឺសំរាប់បុគ្គលគាំងនៅក្នុងផ្ទះ ដែលមិនអាចចេញពីផ្ទះរបស់គេ ទៅកន្លែងចាក់វ៉ាក់សាំងបាន សូម្បីតែដោយមានជំនួយក៏ដោយ។ បុគ្គលទាំងនេះគឺត្រូវការ៖**

1. ឡានពេទ្យ ឬជំនួយមនុស្សពីរនាក់ ដើម្បីចេញពីផ្ទះ, ឬ
2. មិនអាចចេញពីផ្ទះបាន សំរាប់ការណាត់ជួបពេទ្យ នៅក្រោមកាលៈទេសៈធម្មតា, ឬ
3. មានការពិបាកខ្លាំង និង/ឬ ត្រូវការគាំទ្រខ្លាំងក្លា ដើម្បីចេញពីផ្ទះ សំរាប់ការណាត់ជួបពេទ្យ។

## របៀបតភ្ជាប់ជាមួយ កម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ រដ្ឋម៉ាសាជូសេត

មានអង្គការនានា ដែលគាំទ្របុគ្គលដែលគាំងនៅក្នុងផ្ទះ ហើយអាចនឹងត្រូវការ នូវការចាក់វ៉ាក់សាំង-ក្នុងផ្ទះ អាចនឹងបានបញ្ជូនទៅ ខ្សែមជ្ឈដ្ឋានចំណូល ការចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ (Homebound Vaccination Central Intake Line) រដ្ឋ បានប្រតិបត្តិការដោយ MassOptions ដើម្បីឲ្យបានត្រួតពិនិត្យ សំរាប់ភាពសមរម្យ សំរាប់ការចាក់វ៉ាក់សាំង-ក្នុងផ្ទះ និងបានតភ្ជាប់ ទៅធនធាន ដើម្បីគ្រោងពេលការចាក់វ៉ាក់សាំង។

**ខ្សែមជ្ឈដ្ឋានចំណូល កម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ**
**1-833-983-0485**
ថ្ងៃច័ន្ទ រហូតថ្ងៃសុក្រ
9:00 ព្រឹក ដល់ 5:00 ល្ងាច

ខ្សែមជ្ឈដ្ឋានចំណូល កម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ គឺមានជាភាសាអង់គ្លេស និងអេស្ប៉ាញ៉ុល ហើយក៏នឹងមានអ្នកបកប្រែ ដើម្បីគាំទ្រប្រជាជន ប្រហែលជា 100 ភាសាថែមទៀត។

## អំពីកម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ រដ្ឋម៉ាសាជូសេត

សំរាប់មនុស្សដែលមិនអាចចេញពីផ្ទះរបស់គេបាន សំរាប់ការណាត់ជួបចាក់វ៉ាក់សាំង សូម្បីតែដោយមានជំនួយក៏ដោយ រដ្ឋ **Commonwealth បានបង្កើតដំណោះស្រាយច្រើនវិធី ដើម្បីធ្វើឲ្យប្រាកដ ថាបុគ្គលទាំងនេះអាចបានចាក់វ៉ាក់សាំងនៅក្នុងផ្ទះរបស់គេ។**

**មានគណៈសុខភាពជាច្រើនក្នុងតំបន់ កំពុងតែចាត់ចែងកម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ របស់ខ្លួនគេ សំរាប់សហគមន៍របស់គេ ទន្ទឹមនឹងនេះ ផ្សេងៗទៀតបានជ្រើសរើសធ្វើជាដៃគូ** ជាមួយកម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះរបស់រដ្ឋ តាមរយៈ Commonwealth Care Alliance (CCA)។

**នៅពេលបុគ្គលម្នាក់ទាក់ទង ខ្សែមជ្ឈដ្ឋានចំណូល កម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ គេអាចនិយាយជាមួយ អ្នកតំណាងម្នាក់ ដែលនឹងសួរសំណួរគេ ដើម្បីសំរេចបើសិនការចាក់វ៉ាក់សាំង-ក្នុងផ្ទះ សាំង-ក្នុងផ្ទះ** (ដូច (ដូចបានឲ្យអត្ថន័យ ខាងលើ)។ ខ្សែមជ្ឈដ្ឋានចំណូល កម្មវិធីចាក់វ៉ាក់សាំងឲ្យអ្នកគាំងនៅក្នុងផ្ទះ គឺអាចគាំទ្របុគ្គល ជាមួយការត្រួតពិនិត្យ សំរាប់ ចាក់វ៉ាក់សាំងក្នុងផ្ទះ តែប៉ុណ្ណោះ ហើយអ្នកតំណាង មិនអាចគ្រោងពេល ការណាត់ជួបចាក់វ៉ាក់សាំងទូទៅ ឬឆ្លើយសំណួរ ទូទៅអំពី COVID-19 ឬផ្តល់ដំបូន្មាន ការថែទាំសុខភាពរបស់បុគ្គល បានឡើយ។

**បើសិនការចាក់វ៉ាក់សាំង-ក្នុងផ្ទះ គឺសមរម្យ គេនឹងបានចុះឈ្មោះ ជាមួយនឹងអ្នកផ្តល់វ៉ាក់សាំងរដ្ឋ ឲ្យអ្នកគាំងនៅក្នុងផ្ទះ (State Homebound Vaccine Provider), Commonwealth Care Alliance, ឬបានបញ្ជូន ទៅគណៈសុខភាព ក្នុងតំបន់របស់គេ នៅកន្លែងដែលគេរស់នៅ និងថាតើគណៈសុខភាពក្នុងតំបន់របស់គេ កំពុងតែ ផ្តល់ការចាក់វ៉ាក់សាំង -ក្នុងផ្ទះ ឬអត់។**

បើសិនការចាក់វ៉ាក់សាំង-ក្នុងផ្ទះ គឺមិនសមរម្យទេ អ្នកទូរស័ព្ទមក នឹងបានបញ្ជូនទៅធនធានផ្សេងៗទៀត សំរាប់ជំនួយ ដើម្បីគ្រោងការណាត់ពេលជួប នៅកន្លែងចាក់វ៉ាក់សាំងមួយ ឬរកដំណោះស្រាយយានជំនិះ។

**អ្នកផ្តល់វ៉ាក់សាំងរដ្ឋ ឲ្យអ្នកគាំងនៅក្នុងផ្ទះ, Commonwealth Care Alliance នឹងកាន់កាប់ការគ្រោងពេល និងការផ្តល់ នូវការចាក់វ៉ាក់សាំង-ក្នុងផ្ទះ។**

- បុគ្គលដែលបានចុះឈ្មោះ ជាមួយនឹងកម្មវិធីរដ្ឋ នឹងទទួលទូរស័ព្ទមកពី អ្នកផ្តល់វ៉ាក់សាំងរដ្ឋ-ក្នុងផ្ទះ (State In-Home Vaccine Provider) ដើម្បីគ្រោងពេល ការណាត់ជួបចាក់វ៉ាក់សាំង-ក្នុងផ្ទះ ដោយសមរម្យ ក្នុងពេល បីថ្ងៃធ្វើការ នៃការចុះឈ្មោះ។
- អ្នកផ្តល់វ៉ាក់សាំងរដ្ឋ ឲ្យអ្នកគាំងនៅក្នុងផ្ទះ នឹងមានអ្នកវិជ្ជាជីវៈពេទ្យ ជាបុគ្គលិក ដែលនឹងមកដល់ផ្ទះ ដើម្បីចាក់ វ៉ាក់សាំង COVID-19 ស្របតាមគោលការណ៍ណែនាំទាំងអស់ នៃសុខភាពសាធារណៈ។ ក្នុងអំឡុងដំណើរការ គ្រោងពេលនេះ អ្នកចាក់វ៉ាក់សាំង នឹងពិភាក្សាពីសេចក្តីត្រូវការនិមួយៗ នៃបុគ្គលដែលទទួលវ៉ាក់សាំង។ អ្នកចាក់ វ៉ាក់សាំង គឺជាអ្នកវិជ្ជាជីវៈពេទ្យដែលបានហ្វឹកហ្វឺន ដែលបានឆ្លងកាត់ការពិនិត្យប្រវត្តិរូប ប្រព្រឹត្តតាមការអនុវត្តន៍ ល្អបំផុត នៃសុខភាពសាធារណៈ ហើយនឹងមានថ្នាំពេទ្យ ដើម្បីដោះស្រាយប្រតិកម្មអាល់ឡ័រជី។
- អ្នកផ្តល់វ៉ាក់សាំងរដ្ឋ-ក្នុងផ្ទះ នឹងប្រើវ៉ាក់សាំង Janssen របស់ Johnson & Johnson មួយដូស្សដែល FDA បានទទួលស្គាល់។

**ដោយព្រោះការពិចារណាលើហេតុផល ជុំវិញការផុតកំណត់នៃវ៉ាក់សាំង ខណៈនៅក្នុងត្រង់ស៊ីត មនុស្សដែល ទទួលការចាក់វ៉ាក់សាំង-ក្នុងផ្ទះ នឹងបានដាក់ជាក្រុមៗ ដោយយោងតាមភូមិសាស្រ្ត និងមិនមែនយោងតាមការមកមុន បានបំរើមុនទេ។ វាអាចនឹងប្រើពេលជាច្រើនអាទិត្យ ទំរាំបុគ្គលទាំងនេះអាចទទួលការចាក់វ៉ាក់សាំង-ក្នុងផ្ទះ ដោយព្រោះ ហេតុផលឧបសគ្គ ទាំងនេះ។**

សំរាប់បុគ្គលដែលត្រូវការជំនួយ ក្នុងការចុះឈ្មោះជាមុន ឬការគ្រោងពេលណាត់ជួប នៅកន្លែងចាក់វ៉ាក់សាំង សូមហៅ 2-1-1 (877-211-6277)។